# សៀវភៅគតិលោក
# ភាគ ទី៧



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com
កែវ បន្ទុបុរាណ

# រឿងមេឆ្កែខ្លាចអសុព

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានមេសុនខ១ នាំកូនទៅស្វែងរកអាហារបរិភោគលុះទៅដល់ព្រៃទីបាឆាមួយបានឃើញសាកសពខ្មោចកំពុងហើម គេចោលនៅទីប៉ាឆានោះ មេសុនខក៏នាំកូនចូលទៅ ទើបកូនសួរទៅមេថា ម៉ែៗនេះគេហៅអ្វីៗ?ៗ មេសុនខក៏ប្រាប់ថា "រូបនេះគឺខ្មោចមនុស្សណាកូនគេយកមកចោលនៅទីនេះ"ៗ កូនឆ្កែឮមេប្រាប់ជាខ្មោចមនុស្សដូច្នោះ ក៏កើតចំណង់ចង់ស៊ីខ្មោចនោះ ទើបថា "ម៉ែ ខ្ញុំចង់ស៊ីភ្នែកវាជាមុន"ៗ មេហាមថា "ភ្នែកជាកាឡកណ្ណីចង្រៃណាស់ នឹងស៊ីវាមិនបានទេណាកូនកូន"ៗ កូនឆ្កែសួរថា "ម្ដេចម៉ែឯងថាភ្នែកជាកាឡកណ្ណីចង្រៃដូច្នោះហះ"ៗ

មេឆ្កែប្រាប់ថា "ភ្នែកនេះកាលវារស់នៅ វាតែងសម្លឹងសម្លក់មើលនូវរូបបារម្មណ៍ផ្សេងៗ មានរូបស្រីដើម ភ្នែកនេះកាលបើវាយល់រូបល្អ រូបគាប់ចិត្តហើយវានាំចិត្តឲ្យប្រាថ្នាលោភចង់បានរូបនោះៗ បើពុំបានវានាំចិត្តឲ្យសៅសោកក្ដៅក្រហាយបណ្ដាលឲ្យហ៊ានធ្វើនូវអំពើបាបលាមកមានព្យាបាទជាដើម ហេតុនេះទើបថាភ្នែកនេះ ជាកាឡកណ្ណីចង្រៃក្រៃពេកណាស់



កូនឯងកុំស៊ីភ្នែកនោះឡើយ"ៗ កូនឆ្កែបានស្ដាប់មេអធិប្បាយទោសភ្នែកដូច្នោះហើយ ទើបថា "បើដូច្នោះខ្ញុំនឹងស៊ីត្រចៀកវិញចុះ"ៗ មេឆ្កែក៏ហាមថា "ត្រចៀកនេះក៏ជាកាឡកណ្ណីចង្រៃដូចគ្នា គឺកាលវារស់នៅនោះវាចង់ស្ដាប់សព្ទសម្លេងទាំងឡាយមានសម្លេងស្រីតូរ្យតន្ត្រីជាដើម ត្រចៀកនេះវានាំកាយឲ្យត្រាប់ដើរស្ដាប់សព្ទសម្លេងទាំងពួង សម្លេងណាពីរោះវានាំចិត្តឲ្យសោមនស្សត្រេកអរ សម្លេងណារឹងគ្រោតមិនពីរោះ ឬឮសម្លេងអ្នកដែលជាសត្រូវនឹងខ្លួន វានាំចិត្តឲ្យទោមនស្សខាត់ខឹង ចងអាឃាតព្យាបាទឡើងហេតុនោះ ទើបថា ត្រចៀកនេះជាអាយតនៈកាឡកណ្ណីចង្រៃក្នុងលោកនេះ មិនគួរកូននឹងវាឡើយ"ៗ កូនឆ្កែថា "បើដូច្នោះខ្ញុំស៊ីច្រមុះវិញចុះ"ៗ មេឆ្កែក៏ហាមថា "ច្រមុះក៏ជាកាឡកណ្ណីដូចគ្នា គឺកាលវារស់នៅនោះវាចង់ថើបចង់ស្រូបហិតក្លិនផ្សេង ក្លិនឯណាក្រអូបវានាំចិត្តឲ្យប្រាថ្នា ក្លិនឯណាស្អុយឆ្អាបឆ្អេះ វានាំចិត្តឲ្យក្ដៅក្រហាយណាយស្អប់ខ្ពើមឆ្អើមហេតុនោះទើបថាច្រមុះនេះជាអាយតនៈកាឡកណ្ណី មិនគប្បីកូនចង់ស៊ីវាឡើយ"ៗ កូនឆ្កែក៏ថា ដូច្នោះខ្ញុំនឹងស៊ីមាត់ ស៊ីអណ្ដាតជាបានឬមិនបានណាម៉ែ?ៗ មេឆ្កែក៏ហាមទៀតថា "មាត់នឹង

អណ្តាតជាកឡកណ្ណីចង្រៃលើសលែងឯងទៀតៗគឺមាត់នេះកាល
នៅរស់នោះ វានិយាយមុសាកុហកគេ វាជេរពោលប្រទេចផ្តា
សាគេ វាញុះញង់ស្តីបំបាក់បំបែកគេ វាស្តីដើមពោលបង្កាច់
បង្កិនគេជាដើមយ៉ាងនេះ ឯអណ្តាតនោះសោត ក៏ជាអាយតនះ
ពាល់ត្រូវតែរសជាតិមាហារ វាប្រាថ្នាតែវត្ថុឆ្ងាញ់ពីសា បើបាន
ពាល់ត្រូវរសឆ្ងាញ់ពីរបស់ណាហើយ វានាំចិត្តឲ្យប្រាថ្នាចង់បាន
ឡើយទៀត បើពាល់ត្រូវលើរសមិនឆ្ងាញ់ពីសាកាលណា វានាំ
ចិត្តឲ្យក្តៅក្រហល់ក្រហាយទៅផ្សេងៗ ហេតុនេះទើបថាមាត់
អណ្តាតនេះជាអាយតនះកាឡកណ្ណី មិនគប្បីស៊ីវាឡើយ"ៗ
កូនឆ្កែថា "បើដូច្នោះខ្ញុំនឹងស៊ីដៃវិញយ៉ាងនេះតើគួរឬម្តេច?ៗ
មេឆ្កែក៏ហាមវិញទៀតថា "ដៃក៏ស៊ីមិនបានដូចគ្នា ដៃនេះកាល
វារស់នៅនោះវាតែងចាប់ដំបងព្រនង់គ្រឿងសស្ត្រាវុធ
ប្រហារវាយចាក់កាប់សម្លាប់មនុស្ស ជួនណាវាឆក់យកទ្រព្យ
សម្បត្តិគេនានា នាំរូបវាឲ្យបានក្តីទុក្ខជាប់គុកជាប់តារាងខ្នោះ
ឃ្នាងទៅផ្សេងៗ ហេតុនោះទើបថាដៃនេះជាកាឡកណ្ណីចង្រៃ
លើសគេ មិនគួរនឹងបរិភោគវាឡើយ"ៗ កូនឆ្កែថា "បើដូច្នោះ
ខ្ញុំនឹងបរិភោគជើងវាចុះ"ៗ មេឆ្កែក៏ហាមទៀតថា "ជើងក៏ជា



កាឡកណ្ណីដូចគ្នាកាលវារស់នៅ ជើងនោះសោតវានាំរូបដើរ
ត្រាច់ចរទៅលេងទៅមើលទៅស្តាប់ទៅលួចទៅប្លន់គេ ជួន
កាលវាដើរទៅជាន់លាមកជាន់បន្លា ជាន់លើកម្រាលអាសនៈ
ព្រះភិក្ខុសង្ឃជាទីមិនគួរជាន់ ជួនណាវាដើរទៅជាន់ជើងចោរ
នាំឲ្យគេគិតចិត្តសង្ស័យថាខ្លួនជាចោរជាអ្នកដើរយប់គប់ពាល
សាមាន្យ បានក្តីទុក្ខទោសក្នុងលោកិយ ហេតុនេះទើបថាជើង
នេះជាមហាចង្រៃកាឡកណ្ណី មិនគួរគប្បីបរិភោគវាឡើយ"ៗ
កូនឆ្កែថា "បើដូច្នោះខ្ញុំនឹងស៊ីពោះពុងវិញ"ៗ មេឆ្កែហាមទៀត
ថាពោះពុងនោះជាលំនៅនៃចិត្តៗ នោះហៅមនោសវនេះជា
អាយតនៈទទួលធម្មារម្មណ៍ នាំតាមគំនិតដែលគិតគឺ គិតចង់បាន
ទ្រព្យសម្បត្តិ ប្រាថ្នាយសសក្តិជាគ្រឿងលោកិយ តាមក្តីវត្ថុកាម
កិលេសតាម គិតចង់ឈ្នះគេ គិតឈ្នានីសគេ គិតលុបគុណគេ គិត
មាក់ងាយគេ គិតព្យាបាទគេ គិតមាយាបិទទោសឯងសំដែងទោ
សគេ គិតសម្លឹងចង់បានទ្រព្យសម្បត្តិគេ គិតែប្រយោជន៍ឯង
មិនបែងប្រយោជន៍ដល់អ្នកដទៃផង ចិត្តគិតក្នុងការអកុសល
យ៉ាងនេះ ទើបថាពោះពុងជាលំនៅនៃចិត្ត ពោះពុងនេះជាកា
ឡកណ្ណីចង្រៃក្រៃពេកណាស់កូនឯងនឹងស៊ីវាពុំបាន ចូរខានទៅ

ចុះកូនកុំស៊ីចំណីកាឡកណ្ណីនេះឡើយ"ៗ

កូនឆ្កែបានស្តាប់មេអធិប្បាយ អំពីចំណីកាឡកណ្ណីដូច្នោះហើយ
ក៏ជឿតាមពុំបានគិតចង់ស៊ីខ្មោចនោះតទៅទៀត ហើយនាំគ្នា
វិលទៅកាន់លំនៅនៃអាត្មាវិញហោងៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកពិចារណាឲ្យឃើញថា អវ
យវៈតូចធំសម្រាប់រូបកាយនេះជាកាឡកណ្ណី កើតដោយក្តីប្រមា
ទមិន ឱហាតបង្ហាត់អវយវៈ ឲ្យដឹកល់នៅក្នុងការសួស្តិមង្គល បុគ្គ
លអ្នករក្សាអវយវៈមិនឲ្យធ្លាក់ចុះជាកាឡកណ្ណីនោះ គឺកាន់ឥន្ទ្រី
យសំវរសីល រក្សាទ្វារទាំង៦ មានចក្ខុទ្វារជាដើម មិនឲ្យបាប
ធម៌ចូលទៅបៀតបៀនចិត្តខាងក្នុងបាន សង្រួមកាយមិនឲ្យ
បាបធម៌ចូលពាល់ត្រូវបាន ប្រដៅកាយឲ្យឆ្ងាយអំពីអកុសល
កម្ម គឺកាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ ដែលហៅថាអកុសល
កម្មបថទាំង១០ នោះឯង ឯសេចក្តីសង្រួមទ្វារទាំង៦ និងការ
តាំងនៅក្នុងកុសលកម្មបថ១០ នោះក្នុងតំរានេះមិនបានសំដែង
ឲ្យពិស្តារទេ មាននៅក្នុងកំរាគតិធម៌ឯណោះហើយ ចូរទៅមើល
យកជាគតិចុះៗ

បុគ្គលរក្សាឥន្ទ្រីយ ៦ វៀរអកុសលកម្មបថ១០ នោះបាន



ឈ្មោះហៅថាធ្វើអវយវៈឲ្យផុតចាកកាឡកណ្ណីចង្រៃ ដូចន័យ
ដែលមេសុនខសំដែងប្រាប់កូនវានោះឯង អញ្ជើញអ្នកប្រាជ្ញ
គិតទៅទៀតចុះៗ

**ចប់តម្រាអវយវៈកាឡកណ្ណីទី ៣៥។**

## រឿងនាយដង្ហៅនិងកូនឈ្នួល

មាននាយដង្ហៅម្នាក់ ទៅជួញបានចំណេញមកមានក្តីសប្បាយ
ចិត្ត គិតនឹងលៀងអស់បណ្តាមហាជនជាញាតិមិត្រក្នុងលំនៅនៃ
អាត្មា ទើបប្រើបោយឲ្យទៅផ្សារទិញម្ហូបចំណីហើយផ្តាំថា
"ចូរចៅឯងទិញត្រីទិញសាច់រើសរកតែល្អៗ យកមកឲ្យយើង
ធ្វើម្ហូបលៀងពួកញាតិមិត្តដែលនៅជិតនេះឲ្យសប្បាយម្តង"ៗ

ឯចៅបោយក៏ទទួលពាក្យនាយ យកប្រាក់អំពីនាយស្តាយត្រក
ដើរទៅផ្សារធំ លុះទៅដល់ផ្សារចៅបោយគិតថា នាយអញ
គាត់ផ្តាំថាឲ្យទិញសាច់អណ្តាតសត្វចុះ សាច់អណ្តាតនោះល្អហើយ
គិតហើយចៅបោយទិញសុទ្ធតែអណ្តាតសត្វទាំងឡាយមាន
អណ្តាតគោជាដើម បានហើយក៏ដោតជាត្រណោតយួរមកដល់
ផ្ទះជូននាយដង្ហៅនោះៗ នាយដង្ហៅយល់អណ្តាតសត្វដូច្នោះ
ហើយក៏ស្តីបន្ទោសទៅថា "យើងឲ្យទៅទិញយកសាប់ល្អៗចុះ

ហេតុអ្វីចៅទិញយកតែអណ្តាតគោ អណ្តាតជ្រូក អណ្តាតពពែ មកដូច្នេះនេះហើយឬជាសាច់ល្អ? ។ ចៅបាយក៏អធិប្បាយថា "សាច់អណ្តាតនេះហើយលោកនាយ ដែលជាសាច់ល្អលើសសាច់ទាំងពួងបានជាខ្ញុំបាទថាល្អនោះ ព្រោះខ្ញុំយល់ថា លោកអ្នកបានយសបានសក្តិ បានមាស បានប្រាក់ បានខ្ញុំកំដរ បានជាមេជាបាគេក្នុងលោកនេះ សឹងអាស្រ័យបានដោយអណ្តាតក្រលៀសពោលឡើង ហេតុនេះទើបលោកសន្មតថាអណ្តាតនេះជាសាច់ល្អលើសលែងសាច់នានា បានជាខ្ញុំបាទទិញយកមកនេះ" ។ នាយដំឡៅបានឮចៅបាយឆ្លើយតបដោយវោហារដូច្នោះក៏ទាល់សេចក្តីមិនអាចថាអ្វីតទៅទៀតឡើយ បានក្តីខ្មាសនឹងពាក្យចៅបាយទៅទិញសាច់ម្តងទៀត បានផ្តាំថា ចូរទិញយកសាច់អាក្រក់ៗមកចុះ យើងនឹងធ្វើម្ហូបលៀងភ្ញៀវ ។

ចៅបាយទទួលប្រាក់ទទួលពាក្យហើយក៏ទៅផ្សារ ដល់ហើយក៏ទិញអណ្តាតសត្វដូចកាលមុនបានហើយ ក៏នាំយកមកជូននាយដំឡៅៗយល់អណ្តាតសត្វដូចមុនដូច្នោះ ក៏ស្តីបន្ទោសថា ពិម្សិលមិញយើងឲ្យទៅទិញសាច់ល្អៗ ចៅឯងទិញយកអណ្តាតសត្វមក ហើយពោលថាអណ្តាតនេះហើយ ជាសាច់ល្អលើស



លែងសាច់ឯទៀតៗ ឥឡូវថ្ងៃនេះយើងផ្តាំថាឲ្យទិញសាប់អាក្រក់ៗ ហេតុអ្វីក៏ចៅទិញអណ្តាតសត្វដែលចៅអួតថាសាប់ល្អនោះមកទៀត ។

ចៅបាយក៏ឆ្លើយកែសំនួនថា "សាច់អណ្តាតនេះហើយលោកនាយ ដែលជាសាច់អាក្រក់លើសលែងសាច់ឯទៀតៗ បានជាខ្ញុំបាទថាអាក្រក់នោះ ព្រោះអណ្តាតនេះឯងវាក្រលៀវក្រលៀសពោលបង្កាច់បង្កិនគេ ត្មះតិះដៀល ជេរប្រទេច ផ្តាសា ស្តីមុសា កុហកបញ្ជុកបញ្ឆោតគេ ញុះញង់ស៊កសៀត បំបែកបំបាក់គេទៅផ្សេងៗ ហេតុនេះឯងទើបលោកសន្មតថាអណ្តាតនេះជាសាច់អាក្រក់លើសលែងសាច់នានាក្នុងលោកិយនេះ បានជាខ្ញុំបាទទិញមកតាមប្រសាសន៍ដែលលោកនាយផ្តាំ ថាឲ្យទិញសាប់អាក្រក់នោះឯង ។ នាយដំឡៅ បានស្តាប់ពាក្យចៅបាយពោលដូច្នោះក៏ទាល់សេចក្តី ពុំអាចថាអ្វីទៅទៀតបាន ដោយអាត្មាចាញ់ប្រាជ្ញាចៅបាយ ដោយប្រការដូច្នេះហោង ។

រឿងនេះ បានគតិដល់បុគ្គលដែលធ្វើជានាយចៅហ្វាយឬជាគ្រូអាចារ្យមេបាគេ កាលនឹងប្រើបាវប្រើសិស្សឲ្យទៅយកអ្វីៗ គប្បីបញ្ជាក់ពាក្យបណ្តាំឲ្យអ្នកបំរើនោះស្តាប់ចូលចិត្ត

សេចក្ដីឲ្យបានច្បាស់ ទើបការនោះមិនប្រែខ្វែងទៅបាន ។

មួយទៀត ជាតិអ្នកតូចនឹងទទួលពាក្យបណ្ដាំអ្នកធំនោះច្រើនតែរហ័យហួស ស្ដាប់មិនទាន់ជាក់ប្រញាប់តែមីតរត់ទៅមិនដឹងជាយកអ្វីហៅនរណាឲ្យទៅ ម្ល៉ោះហើយប្រមាណយកផ្ដេសផ្ដាសទៅ មិនត្រូវនឹងពាក្យបណ្ដាំលោក ដូចយ៉ាងកូនសិស្សលោកព្រះមហាវិមលធម្ម ឈ្មោះចៅឡុងលោកគ្រូប្រើឲ្យសួររកចិត្រមូលភ្លើងនឹងលោកអាចារ្យអួង ចៅឡុងស្ដាប់មិនច្បាស់ក៏រត់ទៅដល់ផ្ទះម៉ាស៊ីនទឹកកក រងមើលក្រែងភ្លើងឆេះផ្ទះ លុះពុំឃើញមានអ្វី ក៏វិលមកទូលលោកវិញថា ភ្លើងម៉ាស៊ីទឹកកកមិនមានឆេះផ្ទះគេទេ ។

លោកគ្រូបានឮដូច្នោះ ក៏ថាអញឲ្យសួរលោកអាចារ្យអួងជាលោកមានចិត្រមូលភ្លើងឬទេ បើលោកមាន ឲ្យសុំលោកបន្តិចមកនឹងធ្វើថ្នាំ ចុះហេតុអ្វីក៏ចៅទៅដល់ផ្ទះម៉ាស៊ីនទឹកកកហើយថាភ្លើងឆេះផ្ទះអាណាគេប្រើឯងឲ្យទៅមើលភ្លើងឆេះផ្ទះនោះចៅឯងជាមនុស្សស្ដាប់ការគេមិនជាក់ មិនសួរសព្ទឲ្យចូលចិត្តសិន លោកព្រះមហាវិមលធម្មក៏បន្ទោសចៅនោះដោយប្រការផ្សេងៗហោង ។



មានរឿងចៅម្នាក់ទៀត ឈ្មោះសោមចៅនោះជាកូនសិស្សលោកសម្ដេចព្រះសុគន្ធាធិបតី ថ្ងៃមួយមានពួកទាយកអ្នកមុខអ្នកការ គេមកថ្វាយទានដល់លោកៗប្រើចៅនោះថា "ចូរទៅយកពានមួយមកដើម្បីនឹងដាក់ស្លាបារី ចែកពួកទាយកអាស្រ័យ" ។ ឯចៅនោះស្ដាប់សព្ទមិនច្បាស់ ក៏ផ្ដាសចេញទៅលីពាងទឹកមួយចូលមកនាកណ្ដាលជំនុំប្រជុំជនធ្ងន់ណាស់ក៏ទូលថា "សូមមេត្ដាប្រោសដាក់ត្រង់ណាពាងនេះ" ។ ឯមហាជនទាំងឡាយមានលោកសម្ដេចព្រះសុគន្ធាធិបតីជាប្រធាន ក៏សើចកងរំពងឡើងថា ចៅនេះជាមនុស្សរហ័សហួសជ្រួសសេចក្ដី គេប្រើឲ្យយកពាន ពុំមានសបសួរឲ្យជាក់ច្បាស់ ផ្ដាសទៅយកពាងទឹកមកវិញ បានក្ដីអៀនខ្មាសនាកណ្ដាលជំនុំហោង ។ មួយទៀតលោកអ្នកធំប្រើថ្លែងសព្ទមិនអស់ចុងអស់ដើម ពាក្យសព្ទនោះជួនស្របគ្នា អ្នកបំរើស្ដាប់បានហើយ តែចង់បង្កាច់ឲ្យខុសវិញក៏បាននឹងបន្ទោសអ្នកបំរើវិញពុំបាន ដូចនិទានចៅវ៉ាយគងមានទំនងសព្ទស្របគ្នានោះឯង នឹងសំដែងឲ្យចូលចិត្តរឿងប្រឡំសព្ទនោះថា៖

## រឿងបុរសចេះវ៉ាយគង

មានឧបាសកម្នាក់ក្នុងជនបទមួយគិតបំបួសកូនក្នុងខែបង់មា
សាធ បានទៅនិយាយជួលភ្លេងពិណពាទ្យគេជាដាច់ខាតលុះដល់
ថ្ងៃចូលរោងប្រជុំជាតិនឹងចំរើនពុទ្ធមន្តហៅព្រលឹងនាគនោះ
ពួកអ្នកភ្លេងនាំគ្រឿងភ្លេងចូលមកគ្រប់គ្នាទាំងអស់ តែអ្នក
ចេះវាយគងមកពុំបាន ព្រោះប្រពន្ធឆ្លងទន្លេ ផ្តាំតែពាក្យមក
នឹងអ្នកភ្លេងផងគ្នាថា ឲ្យជំរាបអ្នកដើមបុណ្យផងថា មកពុំបាន
ទេព្រោះប្រពន្ធឆ្លងទន្លេឲ្យអ្នកដើមបុណ្យគិតរកជួលគេឯ
ទៀតចុះ ។

ឯអ្នកដើមបុណ្យនឹងបណ្តាមហាជនទាំងឡាយបានឮថាអ្នក
វាយគងនោះ ទានពុំបានមកដូច្នោះក៏ប្រជុំពិគ្រោះគ្នាថា នឹងទៅ
រកជួលមនុស្សចេះវាយគងថាស ចៅនោះពិគ្រោះទៅរកពុំ
បាន ព្រោះស្រុកក្រោមមនុស្សចេះភ្លេងមានតិចនាក់ហើយពេល
នោះក៏ជួនល្ងាចណាស់ហើយ នឹងទៅរកអ្នកចេះឯណាៗក៏ពុំទាន់
ម្ល៉ោះហើយ ពួកអ្នកធ្វើបុណ្យទាំងនោះ ពុំសូវរីករាយសប្បាយ
ព្រោះមិនពេញក្តីប្រាថ្នានៃអាត្មាទីទៃៗ ។

គ្រាកាលនោះ មានអាម្នាក់មាននាមពុំប្រាកដសន្មតហៅ ចៅ
ប្លមបាយបុណ្យចៅនោះដើរទៅដល់យល់រោងគេធ្វើបុណ្យក៏



គិតថា អ្នកស្រុកនេះគេធ្វើបុណ្យ គួរអញចូលទៅប្រចុប្រ
ចែងយកបាយចំណីបារីស្លាអាស្រ័យ គិតហើយក៏ចូលទៅក្នុងរោង
បុណ្យអង្គុយនៅទីដ៏គួរ សួរគេថា "អ្នកបងអ្នកប្អូនអើយ! ចុះ
គេធ្វើបុណ្យអីនេះអ្នក?។ ពួកអ្នករោងប្រាប់ថា "គេធ្វើបុណ្យ
បំបួសនាគណាអ្នក" ។ "ចុះអ្នកឯងមកពីស្រុកណាទៅណា?។
ចៅនោះក៏ប្រាប់ថា "ខ្ញុំមកពីក្រុងភ្នំពេញនឹងទៅសួរបងប្អូន
ឯស្រុកលើ ចុះខ្ញុំឮគេអោយពិគ្រោះគ្នាអ៊ូៗនោះ តើគេពិគ្រោះ
ពីរឿងអ្វី?។ ពួកអ្នករោងប្រាប់ថា "ឱអ្នកអើយ ការបុណ្យនេះ
បានទៅ និយាយជួលភ្លេងពិណពាទ្យ គេជាការស្រេចហើយ
ឥឡូវចូលរោងថ្ងៃនេះ ស្រាប់តែអ្នកដែលវាយគងគ្នាមានធុរៈ
ដោយប្រពន្ធឆ្លងទន្លេមកពុំរួច ហេតុនោះទើបគេនាំគ្នាពិគ្រោះ
ឆោឡោ ដើម្បីនឹងរកអ្នកចេះវាយគង អើអ្នកអត់ទោសចុះ
ខ្លួនអ្នកនេះតើចេះវាយគងដែរឬ?។ ចៅនោះក៏ទទួលថា
"ក្រអ្វីសព្វបើវាយគងនោះ ឯងក៏ចេះវាយបាន" ។ ឯពួកអ្នករោង
បានឮពាក្យចៅនោះថាចេះដូច្នោះ ក៏ត្រេអរគឹកកងឡើង
ប្រាប់គ្នាថា "អ្នកវាយគងនោះបានហើយ" ។ ខ្លះសួរថា"អ្នកយក
ថ្លៃប៉ុន្មានក្នុងរវាងបុណ្យនេះ" ។

ចៅនោះថា "ខ្ញុំបាទយកកំលាំងចូលចាប់កុសលផង ត្រង់ថ្លៃថ្នូរនោះខ្ញុំមិនយកទេ សូមទានតែបាយចំណីអាស្រ័យជាកំលាំងចុះ"។

អ្នកដើមបុណ្យឮដូច្នោះ ក៏ត្រេកអរពេញចិត្តដោយគិតថាសមក្ដីប្រាថ្នា ទើបរៀបបាយចំណីស្លាបារី អញ្ជើញចៅនោះបរិភោគតាមក្ដីរាប់អាន ចៅនោះបានបរិភោគបាយចំណីបរិបូណ៌ លុះស្រេចកិច្ចបាយហើយ អ្នកដើមបុណ្យក៏ថាអញ្ជើញអ្នកទៅឯទីភ្លេង ដ្បិតពេលនេះល្មមហ៊ុំរោងហើយ។ ចៅនោះក៏ស្រវាយកស្លាបារីអំពីជើងពាន ដាក់ថ្នក់ដាក់ហោប៉ៅអាវ ហើយក្រោកដើរទៅជាមួយ នឹងអ្នកដើមបុណ្យ។ នាំទៅដល់ក៏ប្រាប់ពួកអ្នកភ្លេងថា ខ្ញុំបានអ្នកវាយគងហើយ ចូរកុំមានក្ដីរង្កៀសអ្វីឡើយ ដោយពុំមែនវង់ជាមួយគ្នា សូមមេត្តាលេងយកតែបុណ្យទៅ ត្រង់ពីរោះ មិនពីរោះនោះ គ្មាននរណាថាអ្វីទេ។ ឯអ្នកភ្លេងទាំង៤នាក់ក៏ព្រមតាមអធ្យាស្រ័យ ទើបថាអញ្ជើញអ្នកចូលមកចុះ ឯអ្នកដើមបុណ្យអញ្ជើញអ្នកចូលក្នុងវង់គងនេះចុះ។

ឯចៅនោះបែរមើលនាយមើលអាយហើយលើកដៃឡើងថា "ខ្ញុំបាទចេះតែវាយគងធំៗ ឮមូងៗ នោះទេត្រង់គងវង់នេះខ្ញុំមិនចេះទេ"។



ឯបណ្ដាមហាជនទាំងឡាយបានឮពាក្យចៅនោះថាដូច្នោះ ក៏សើចកងរំពងឡើង អ្នកខ្លះនឹងលួចជេរថា ខ្មោចអាចង្រៃកោងឆយកបាយមួយថាសស៊ីតែម្ដង ថាវាចេះវាយគងឯងនឹកស្មានថាវាចេះវាយគងភ្លេងនេះ ឥឡូវវាថាចេះវាយតែគងមូងៗមួយៗ នោះវិញអាណាត្រូវការអីនឹងវាយគងមូងនោះតែកូនក្មេងក៏ចេះវាយបានទូទៅទាំងស្រុក ឱពុទ្ធោអើយពួកយើងនេះចាញ់កលនេះជាម្ដង ឯអ្នកដើមបុណ្យក៏ថា ណ្ហើយចុះការនេះឯងសួរដេញគេមិនអស់ចុងអស់ដើម គេក៏គេចប្រែទៅបានយ៉ាងនេះ នឹងបន្ទោសឬនឹងអួសយកបាយចំណីវិញឯណាក៏បានគឺក្ដីខុសមាននៅលើខ្លួនឯងតែម្ដង ថាហើយអ្នកដើមបុណ្យក៏ឲ្យអ្នកភ្លេង៤ នាក់លេងភ្លេងតាមទំនៀមទៅហោង។

អ្នកធំក៏ខូច អ្នកតូចក៏ខិល រកិលផុតបន្ទោសហេតុនោះនឹងប្រើត្រូវប្រយ័ត្នសព្វស្រប កុំឲ្យអ្នកតូចវាប្រកបគេចកែប្រែទៅបាន។

**ចប់តម្រាគតិប្រើមិនអស់ការទី ៣៦។**

# រឿងបុរសអាពុកនឹងកូននាំលាទៅលក់

មានបុរសម្នាក់ ឈ្មោះចៅខែកនឹងកូនប្រុសគាត់ម្នាក់ បានចិញ្ចឹមកូនលា១ ជាសត្វពាហនៈ លុះកូនលានោះចំរើនធំឡើងប្រកបរូបធាត់ល្អ ចៅអាពុកនឹងកូនពិគ្រោះគ្នាថា លាយើងធាត់ធំល្អហើយ បើនាំទៅលក់ឲ្យគេ ក្នុងសម័យនេះ យល់ជានឹងបានថ្លៃច្រើនព្រោះកំពុងធាត់ល្អ តែថានឹងដឹកនាំទៅដល់ស្រុកកំពង់ដែលមានគេត្រូវការទិញនោះឆ្ងាយណាស់ទម្រាំដល់ទៅ លាយើងនេះ យល់ជានឹងស្គមប្រាកដ ដល់លក់មុខជានឹងថោកបានថ្លៃតិចមិនខាន បើដូច្នេះមានតែយើងគិតសែងវាទៅ កុំឲ្យវាដើរខ្លួនវាក្រែងស្គមទៅលក់មិនបានថ្លៃៗ អាពុកនឹងកូនគិតព្រមគ្នាហើយ ទើបចាប់លាមកចងជើងទាំង៤ យកឈើវែងសឹកជាស្នែង នាំគ្នាសែងចេញចាកគ្រឹះស្ថាន លុះទៅដល់ទ្វារស្រុក ពួកអ្នកស្រុកបានឃើញអ្នកទាំងពីរសែងលាដូច្នោះ ក៏នាំគ្នាសើចកងរំពងឡើងហើយតិះដៀលថា 'សត្វលាសត្វសេះនេះជាសត្វពាហនៈ គេតែងជិះតែងបរវា មិនដែលមាននរណាទៅលីទៅសែង វាដូចសត្វជ្រូកសត្វក្ងាន់នោះទេ នេះហេតុអ្វីចៅអាពុកនឹងកូន មកនាំគ្នាសែងលា យ៉ាងនេះធ្វើឲ្យខុសគេក្នុង



លោកិយនេះ ទែនចៅទាំងពីរចៅឯងឆ្កួតឬ បានជាមកសែងលាយ៉ាងនេះ ម៉េចក៏មិនជិះបរវាទៅ?ៗ

ឯអាពុកនឹងកូន បានឮអ្នកស្រុកគេនាំគ្នាតិះដៀលខ្លួនដូច្នោះ ទើបពិគ្រោះគ្នាថា "យើងសែងលាវាខុសគេទៅហើយ បើដូច្នេះគួរស្រាយលាចេញគ្នាជិះបរទៅតាមពាក្យគេវិញចុះ តែនឹងជិះវាទាំងពីរនាក់មិនបាន ព្រោះកូនលានៅតូចក្រែងយោងទៅពុំរួច' គិតគ្នាដូច្នោះហើយចៅអាពុកក៏ថា "ណ្ហើយចុះខ្លួនអញនឹងដើរពីក្រោយ ចូរកូនឯងជិះបរវាទៅចុះឯចៅកូនក៏ទទួលតាមពាក្យអាពុក ហើយឡើងជិះលានោះបរទៅហោងៗ

លុះបរទៅដល់ភូមិស្រុកមួយ ពួកអ្នកស្រុកបានឃើញចៅលក់លាមកដល់ ក៏សួរទៅថា "អ្នកឯងជិះបរលានេះនឹងទៅឯណា?ៗ ឯអាពុកនឹងកូនប្រាប់ថា "ជិះបរនាំទៅលក់ឯស្រុកកំពង់ឯនោះ"ៗ អ្នកស្រុកក៏សួរទៅវិញថា" តាដែលស្ពាយទៃដើរពីរខាងក្រោយលានេះ តើគាត់ជាអ្វីនឹងចៅឯងដែលជិះលានេះ"ៗ

ចៅកូនក៏ប្រាប់ទៅថា "គាត់ជាអាពុកខ្ញុំឯងនេះអ្នកសួរមានការអ្វីឬ?ៗ ឯពួកអ្នកស្រុកបានឮចៅនោះប្រាប់ថាអាពុកដូច្នោះក៏នាំគ្នាស្តីត្អះតិះដៀលថា "ចៅនេះជាមនុស្សមិនស្គាល់គុណបិតា

ខ្លួនគួរឬខ្លួនជាកូនជិះលាធ្វើអាការជានាយ ឲ្យអាពុកស្ពាយទៃទ ដើរក្រោយដូចជាខ្ញុំកំដរខ្លួនយ៉ាងនេះ ខ្លួនឯងក្មេង គួរតែដើរ ស្ពាយទៃទ ឲ្យអាពុកគាត់ជិះវិញនោះទើបគួរ ព្រោះគាត់ចាស់ ជាងខ្លួនផង ជាបិតាខ្លួនផង រីយចៅកំឡោះឯងជិះនោះមិនត្រូវ ទេ ចូរចុះចេញពីខ្នងលាឲ្យឆាប់ឲ្យតាចាស់ជាអាពុកឯង ជិះវិញ ទើបត្រូវល្អ ។ ឯចៅអាពុកនឹងកូនបានឮពាក្យពួកអ្នកស្រុកតិះ ដៀលដូច្នោះហើយក៏ថា យើងធ្វើនេះត្រូវគេនិន្ទាហើយ បើ ដូច្នេះគួរអាពុកឡើងជិះវិញចុះ កូននឹងដើរមុខនាំផ្លូវទៅវិញ កាលបើគិតព្រមព្រៀងគ្នាហើយ ចៅកូនក៏ចុះពីខ្នងលា យកសំ ពាយទៃទពីបិតាស្ពាយដើរមុខ ចៅអាពុកក៏ឡើងជិះលាបរចេរ ទៅតាមមាគ៌ាឆ្ពោះ ស្រុកកំពង់នោះហោង ។

លុះបរទៅដល់អណ្ដូងទឹក នៅចុងស្រុកមួយមានពួកស្រីក្រមុំ ទាំងឡាយវានាំគ្នាដងទឹកអណ្ដូងនោះវាបានឃើញចៅកំឡោះ រូបល្អដើរមុខលា ឃើញតាចាស់ជិះលាបរដល់មក វាក៏នាំគ្នា មើលដោយជាតិស្រីក្រមុំគាប់ចិត្តតែនឹងកំឡោះ ត្រង់មនុស្ស ចាស់ជរានោះ ពុំគាប់ចិត្តឡើយ ហើយវានាំគ្នាត្មះតិះដៀលតា ចាស់នោះថា "កូនលាធាត់ល្អណាស់ សមគួរតែអ្នកកំឡោះដែល



ដើរមុខនោះជិះវិញទើបល្អ នេះឲ្យតាកញ្ចាស់មុខស្រមូមដូច ស្វាឪជិះ យ៉ាងនេះហៅពេញអាក្រក់ក្រៃពេកណាស់ នែតា កញ្ចាស់អើយ! ចុះចេញទៅកុំជិះមិនសមល្អទេ មើលទៅដូច ពានរជិះលា ចូរឲ្យអ្នកកំឡោះគេជិះវិញ ទើបគាប់ភ្នែកយើង ព្រោះរូបលាក៏ល្អត្រូវនឹងអ្នកកំឡោះល្អដូចគ្នា" ។

ឯចៅកូនបានឮស្រីក្រមុំថាដូច្នោះ ក៏បែរទៅនិយាយនឹងអា ពុកថា "ឪអើយ ឥឡូវវាខុសទៅទៀតហើយ គឺពួកមេអស់នេះ វាត្មះតិះដៀលឪឯងថា ដូចជាពានរជិះលា ហើយវាថាឲ្យខ្ញុំជិះ វិញទើបល្អយ៉ាងនេះ តើឪនឹងគិតយ៉ាងណាទៅទៀត? ។

អាពុកតបថា "កាលមុនឯងជិះក៏ខុសម្ដងទៅហើយ ដល់ឥឡូវ អញជិះក៏ខុសទៅទៀត បើដូច្នេះចូរកូនឯងឡើងមកជិះខាង មុខ ជាពីរនាក់នឹងអាពុកបរទៅទៀតហើយ ជាមិនគាប់ចិត្ត មនុស្សពួកណាទៅមុខទៀត" ។

ឯចៅកូនក៏ឡើងជិះលាអង្គុយខាងមុខអាពុក បរលាឆ្ពោះទៅ ហោង លុះបរមកដល់ផ្ទះគយដែលតាំងនៅនាដើមផ្លូវ មេគយ បែរមកឃើញអ្នកទាំងពីរជិះលា ក៏ចុះទៅសួរថា "អ្នកទាំងពីរ ជិះលានេះនឹងទៅឯណា" ។ ចៅអាពុកនឹងកូនប្រាប់ថា "នឹងទៅ

លក់លានេះឯស្រុកកំពង់ឯណោះ"។ មេគយក៏ត្មះតិះដៀលថា "កូនលានេះគ្នានៅស្ទាវស្ទើរណាស់ ហេតុអ្វីចៅឯងប្រួតគ្នាជិះវា យ៉ាងថ្នាក់នឹង បើប្រួតគ្នាជិះម្ដងៗ តើគ្នានឹងធន់បោលបរទៅម្ដេចបាន ទំរាំទៅដល់ស្រុកកំពង់លានេះ ឃើញជាបមបាក់កំឡាំងលក់ពុំបានចំណេញប្រាកដពុំខាន អ្នកឯងឆ្កួតទេឬ កូនលាគ្នានៅតូចហើយមកប្រួតជិះគ្នាយ៉ាងនេះ ម្ដេចមិនដឹកនាំទៅវិញ?។

ចៅអាពុកនឹងកូនបានឮមេគយបន្ទោសដូច្នោះក៏ចុះពីខ្នងលា នាំគ្នាដឹកបណ្ដើរលានោះ ឆ្ពោះទៅកាន់ស្រុកកំពង់នោះហោង។

លុះមកដល់ទីព្រៃចំការមួយ ពុំមានផ្លូវនឹងដឹកទៅទើបអាពុកនឹងកូន នាំគ្នាដឹកលាដើរកាត់ចំការ ដែលគេមិនទាន់ធ្វើស្រេច ដើរកាត់រកផ្លូវនឹងទៅទៀត អ្នកាប់ចំការបានឃើញចៅទាំងពីរ ដឹកលាដើរកាត់ចំការដូច្នោះ ក៏ស្រែកទៅថា "នែអ្នកដឹកលា ទីចំការយើងនេះ យើងមិនទាន់កាប់គាស់ ដុតរំលីងឲ្យស្អាតទេ សឹងប្រកបដោយបន្លាដំឡូងខ្យា បន្លាឃ្លេ បន្លាឫស្សីជាដើម អ្នកដើរទៅមកតោងប្រយ័ត្នបន្លាវាមុតអើរូបអ្នកឯង មានលាជាពាហនៈសម្រាប់ជិះ ម្ដេចឡើយមិនជិះវា ទៅនាំគ្នាដឹកវាវិញ



អ្នកឯងឆ្កួតទេឬ មានលាហើយមិនជិះស៊ូដឹកដើរឲ្យបន្លាមុត ដូច្នេះ នែអ្នកដឹកលាអើយ! ចូរនាំគ្នាឡើងជិះវាទៅទុកវាធ្វើស្ដេចអី លាសេះគេតែងតែជិះវាជាធម្មតានៅនាលោកិយនេះឯង"។

ចៅអាពុកនឹងកូនបានឮអ្នកចំការតិះដៀលដូច្នោះក៏បែរមកនិយាយគ្នាថា "យើងផ្គាប់ចិត្តមនុស្សលោកិយនេះមិនបានទេ កាលដើមយើងនាំគ្នាសែងនោះគេនិន្ទាម្ដងទៅហើយដល់ក្រោយឲ្យកូនជិះក៏ត្រូវគេនិន្ទាថាឯងមិនដឹងគុណអាពុក ដល់ក្រោយឲ្យអាពុកជិះវិញ ត្រូវមេស្រីក្រមុំវាមិនគាប់ចិត្តនឹងតាចាស់វានាំគ្នានិន្ទាផ្សេងៗ ដល់ក្រោយឡើងជិះទាំងពីរនាមេគយ ត្រូវមេគយនិន្ទាថាលាស្ទាវស្ទើរជិះពីរនាក់មិនបាន ដល់ឡូវនេះ យើងដើរដឹកវាវិញ ក៏ត្រូវអ្នកចំការនេះនិន្ទាតិះដៀលថា មានលាហើយម្ដេចក៏មិនជិះអើតម្រាយ៉ាងនេះ តែរូបលាមួយនឹងផ្គាប់លោកិយមិនគាប់ទៅបាន"។

រឿងនេះ បានគតិដល់បុគ្គលអ្នកគិតរកឧបាយកលឲ្យផុតអំពីពាក្យគេនិន្ទា គឺទោះជាចេះយ៉ាងណាៗ ក៏ពុំមានឱកាសនឹងគេចឲ្យផុតពាក្យលោកិយទៅបាន មនុស្សក្នុងលោកិយនេះ

នរណានឹងទៅដាប់ឲ្យត្រូវចិត្តគ្រប់រូបបាននោះ គឺគាប់ឯណោះ ខុសឯណេះយ៉ាងនេះ មានជាធម្មតា កុំថាយើងជាមនុស្សនឹងមនុស្សផ្គាប់គ្នាឡើយ ទោះទេវតាទេវបុត្រផុតវិស័យពីមនុស្ស ក៏ផ្គាប់ពួកមនុស្សមិនត្រូវដូចគ្នា ដូចយ៉ាងសុរិយទេវបុត្ត គឺថ្ងៃរះថ្ងៃលិចមានជាប្រក្រតីសព្វថ្ងៃនេះ វេលាព្រឹកឡើងថ្ងៃរះពីទិសខាងកើតមក លុះល្ងាចថ្ងៃលិចបាត់ពន្លឺទៅទិសខាងលិច សុរិយគតិដើរស្មើដើរមានកំណត់ គឺមួយថ្ងៃ១២ ម៉ោងមួយយប់ ១២ ម៉ោងដូចគ្នា យប់ថ្ងៃមានកំណត់យ៉ាងនេះ នៅផ្គាប់ចិត្តមនុស្សក្នុងលោកិយនេះមិនត្រូវ តង់មានពួកខ្លះថា ថ្ងៃនេះ យប់នេះម្ដេចយូរម្ល៉េះ ម្ដេចឆាប់ម្ល៉េះ ម្ដេចក្ដៅម្ល៉េះ ម្ដេចត្រជាក់ម្ល៉េះ ពោលតិះដៀលយ៉ាងនេះជាដើម ៗ ក៏ឯយប់នឹងថ្ងៃមិនគាប់ចិត្តមនុស្សនោះ ព្រោះមនុស្សនោះមានប្រាថ្នាចង់ឆាប់ចង់យូរដោយចិត្តខ្លួនឯង ដូចយ៉ាងមនុស្សណាដែលត្រូវទោសលោកឲ្យដាក់គុក តែងកំណត់ថាអ្នកឯងនៅ១០ ថ្ងៃឬ១ខែទៀត នឹងរួចចាកទោសនេះ មនុស្សនោះចង់រួចឆាប់ ទន្ទឹងដល់ខែដល់ថ្ងៃនឹងរួច ក៏តាំងរាប់ តាំងគិតទៅ ការដែលរាប់ដែលគិតនោះ ថាថ្ងៃអ្វីក៏យូរម្ល៉េះ ខែអ្វីក៏យូរម្ល៉េះ ពាក្យថាថ្ងៃយឺតយូរ ខែយឺត



យូរនោះ បានខាងមនុស្សដែលចង់រួចពីគុកនោះឯង ៗ

មនុស្សពួកណា ជួលផ្ទះជួលទូកគេនៅលុះដល់ខែម្ចាស់គេទៅទារប្រាក់ឈ្នួល មនុស្សពួកនោះសឹងពោលថាថ្ងៃខែអ្វីក៏ឆាប់ម្ល៉េះ រកតែនឹតរកប្រាក់ម្ដេចទាន់ ៗ ពាក្យថាថ្ងៃខែឆាប់នោះ បានខាងមនុស្សដែលជួលផ្ទះគេនៅនោះឯង ៗ ពាក្យអស់នេះ សមដោយបទបាលីក្នុងគម្ពីរលោកនីតិថា៖

ទីឃា ជាគរតោ រត្តិ
ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលានសង្សារោ
សទ្ធម្មំ អវិជានតំ។

ប្រែថា យប់យូរនៃអ្នកតែងមិនលក់ឯង យោជន៍យូរឆ្ងាយវែងនៃអ្នកចរ សង្សារយូរឆ្ងាយនៃនិករ ពាលពុំចេះធម៌ទៅនិព្វាន ៗ

មួយទៀតលោកថា អ្នកដេកចង់ក្រោកថាយប់យូរ អ្នកដើរគិតគួរថាយោជន៍ឆ្ងាយ ពាលាពុំចេះធម៌ទាំងឡាយ សង្សារវែងឆ្ងាយពីនិព្វាន ៗ

ចប់តម្រាគតិផ្គាប់លោកមិនត្រូវទី ៣៧

# រឿងចៅចាក់ស្មុគ

មានបុរសម្នាក់ហៅថា ចៅចាក់ស្មុគថ្ងៃមួយចៅនោះឡើង ទៅលើចុងត្នោត តាំងកាត់ចៀវស្លឹកត្នោតចាក់ធ្វើជាស្មុគធំៗ បានច្រើនហើយ ក៏ត្រេអរប្រារព្វចាប់បណ្ដើរគិតបណ្ដើរថា អញចាក់ស្មុគបានច្រើនហើយ អញយកទៅលក់ឲ្យគេអញ បានប្រាក់១ រៀល រួចអញទៅទិញមេមាន់គេ បានមកចិញ្ចឹមវាដល់យូរទៅមេមាន់ វាបង្កើតកូនសាយច្រើនឡើងហើយ អញលក់មាន់នោះឲ្យគេ អញបានប្រាក់៥ រៀលហើយអញ ទៅទិញកូនជ្រូកគេមកចិញ្ចឹម លុះកូនជ្រូកនោះធំឡើង អញ លក់ទៅទៀត បានប្រាក់១០រៀល ហើយអញទៅទិញកូន គោ កូនសេះមកចិញ្ចឹម ដល់វាធំឡើងអញលក់ទៅទៀតបាន ប្រាក់កាន់តែច្រើនៗ ឡើងដល់មួយរយពីររយរៀល អញ ទិញស្រែទិញចំការ ទិញភូមិលំនៅៗ ជាសុខសប្បាយហើយ អញធ្វើស្រែបានស្រូវច្រើន អញលក់ស្រូវ លក់ផ្លែឈើបាន ប្រាក់ដល់បីរយបួនរយ អញដណ្ដឹងកូនក្រមុំគេយ៉ាងល្អ ធ្វើជា ភរិយា ដល់នៅយូរទៅ អញមានកូនប្រុសមួយអញស្រឡាញ់ ពេកណាស់អញលោះខ្ញុំស្រីម្នាក់ ឲ្យជាភីលៀងកូនអញកុំឲ្យ



ប្រពន្ធអញវាពិបាកនឹងកូនចៅតទៅ ថាបើមេទាសីនោះ វា បីទ្រពកូនអញមិនប្រយ័ត្ន ធ្វើឲ្យកូនអញដួលចុះ អញនឹងទះ តប់ធាក់ក្បាលវាកុំឲ្យវាធ្លាប់ៗ

ចៅនោះគិតក្លើនសតិទៅដល់ធាក់ទាសី យារជើងធាក់ទៅ លើធាងត្នោត ដោយពេញកំឡាំងក៏ធ្លាក់ចុះចាកចុងត្នោតនោះ មួយរំពេច ចៅនោះមានស្មារតីស្រវាចាប់ចុងស្លឹងត្នោតជាប់ ព្យួរតែងតាង នឹងស្រវាចាប់ធាងឡើងទៅវិញក៏ពុំរួច នឹងទម្លាក់ខ្លួនចុះមកដីខ្លាចក្ដីស្លាប់ ព្រោះត្នោតនោះទ៏លខ្ពស់ ចៅនោះក៏ បានក្ដីទុក្ខវេទនា ដោយតោងចុងស្លឹកត្នោតនោះឯងៗ

គ្រាកាលនោះមានទ្រមាក់ដំរីម្នាក់ បរដំរីមកត្រង់ដើមត្នោត នោះ ទើបចៅស្មុគស្រែកអង្វរទៅថា "ឱ! អ្នកបងអើយ! មេត្តាជួយយកអាយុខ្ញុំបានក្នុងគ្រានេះ ជួយដាក់ខ្ញុំបានផង បើខ្ញុំ បានរួចអាយុម្ដងនេះខ្ញុំនឹងទៅនៅជាខ្ញុំបំរើអ្នកបង"ៗ ឯទ្រមាក់ដំរីបានឃើញបានឮដូច្នោះ ក៏បរដំរីទៅខាងក្រោម ដើមត្នោតហើយក្រោកឈរឡើងលើខ្នងដំរី ងើយទៅនឹងទទួល ចាប់ជើងចៅនោះ នៅពុំទាន់ស៊ប់ល្អញ័រជើងជាន់ខ្នងដំរី ឯដំរី នឹងថាម្ចាស់ឲ្យដើរទៅ វាក៏ដើរចេញអំពីទីនោះទៅ ឯចៅទ្រ

មាក់ក៏ចាប់ជើងចៅចាក់ស្មុគនោះជាប់នៅតែងតោង ទើបស្រែ
អង្វរទៅចៅចាក់ស្មុគវិញថា "ចូរអ្នកចាប់ចុងស្លឹកត្នោតឲ្យជាប់
កុំលែងដៃឡើយ បើខ្ញុំរួចជីវិតម្តងនេះ ខ្ញុំទទួលគុណអ្នកដាក់
លើក្បាលនឹងទៅជាខ្ញុំបំរើអ្នកហោ"។

ឯចៅចាក់ស្មុគរួយដៃណាស់ក៏ស្រែកថា "ចូរលែងចាប់ជើង
យើងទៅ យើងធ្ងន់រួយដៃណាស់ តែខំចាប់យ៉ាងនេះមុខជាស្លាប់
ហើយ ចូរលែងចាប់ជើងយើងទៅ"។

ឯចៅទ្រមាក់ចេះតែអង្វរថា "សូមអ្នកមេត្តាចាប់ខាងលើឲ្យ
ជាប់ ខ្ញុំមិនហ៊ានលែងដៃខ្ញុំពីជើងអ្នកទេ ក្រែងធ្លាក់ស្លាប់ធ្វើម្តេច
ជាគ្រោះកាចនាំឲ្យបានក្តីទុក្ខយ៉ាងនេះ"។

គ្រានោះមានចៅក្បាលទំពែក៤ នាក់នាំគ្នាទៅដឹកអញ្ចង
ឯបឹងធំ ដើរទៅត្រង់ចៅទាំងពីរនោះឯង ចៅទាំងពីរបានឃើ
ញចៅទំពែកទាំង៤នាក់ ក៏ស្តីអង្វរថា "លោកអ៊ុំ លោកមាអើយ
ជួយយកអាយុខ្ញុំបាទផង បើខ្ញុំបាទបានរួចជីវិតហើយ នឹងទៅនៅ
ជាខ្ញុំបំរើលោក"។ ចៅទំពែកបួននាក់ឮដូច្នោះក៏ថា "យើងនឹង
ឡើងទៅជួយដាក់ឯណាបាន បើចៅនៅតែងតោងព្យួរនឹង
ចុងធាងត្នោតយ៉ាងនេះ"។



ចៅទាំងពីរក៏ថា "ឲ្យលោកអ៊ុំ លោកមាឈរកាន់កាងអញ្ចងជា
៤ មុមឲ្យជាប់ខ្ញុំបាទទាំងពីរនាក់នឹងលោតទៅក្នុងអញ្ចងនោះ
ឯង"។

ឯចៅទំពែកទាំង៤ នាក់ក៏ធ្វើតាមទើបនាំគ្នាកាងអញ្ចងជា៤
ជ្រុងហើយយកចុងខ្សែចងព័ទ្ធកវៀងខ្លួនស្រេច ហើយក៏ហៅ
ចៅទាំងពីរនាក់ឲ្យទំលាក់ខ្លួនចុះមក ចៅទាំងពីរក៏ទំលាក់ខ្លួនចុះ
ទៅលើអញ្ចងព្រមគ្នាមួយរំពេច។

ឯអញ្ចងនោះ លុះត្រូវទម្ងន់ចៅពីរនាក់ ក៏ដូចជាគេក្រ្ទាក់
រួបចូលគ្នាចៅទំពែក៤ នាក់ក៏ប្រទាញរួបដូចគេបោលចូល
ទង្គិចក្បាល នឹងក្បាលគ្នាឯងបែកខួរខាងក្នុង ដួលចុះដល់មរណ
កាលទាំងបួននាក់នៅក្រោមដើមត្នោតនោះហោង។

ឯចៅទាំងពីរនាក់បានរួចក្តីស្លាប់អំពីចុងត្នោតហើយបានឃើ
ញចៅទំពែកទាំងបួនស្លាប់ដូច្នោះក៏និយាយគ្នាថា យើងបានរួច
ជីវិតនេះ ព្រោះតាទំពែកគាត់ជួយកាន់អញ្ចងដំឡើង ឲ្យយើង
លោតមកឥឡូវជាកម្មគាត់មកស្លាប់ទាំងអស់ ដូច្នេះយើងនឹងគិត
សងគុណយ៉ាងម៉េច បើយើងនឹងចាត់ចែងដុតដារធ្វើឈាបនកិច្ច
ឆ្លងគុណគាត់ទៅ ក្រែងមេស្រុកចៅហ្វាយស្រុក គេដាក់ទោស

ឯងថាវាយមនុស្សសម្លាប់គេនឹងចាប់ឯងទៅធ្វើទោស នឹងប្រាប់គេតាមត្រង់គេក៏ពុំជឿឯង ព្រោះពុំមានបន្ទាល់សាក្សីជាទីអាងជាការនាំឲ្យកើតទោស កើតទុក្ខទៅមុខទៀតបើដូច្នេះយើងនាំគ្នាកាយដីកប់សពគាត់ហើយ សូមខមាទោសនឹងគាត់ទៅចុះ ។

ចៅទាំងពីរពិគ្រោះយល់ព្រមគ្នាហើយទើបកាយដីកបសពចៅទំពែកទាំង៤នោះ ហើយសំពះស្នាលាទោសតាមទំនៀមស្រេចហើយ ចៅទាំងពីរក៏លាគ្នាទៅកាន់លំនៅនៃអាត្មាទីទៃហោង ។

រឿងនេះ បានគតិដល់បុគ្គលអ្នកគិតវិតក្កតាមអារម្មណ៍នាំបណ្តែតទៅតាមអារម្មណ៍នោះ កើតភ្លើសតិ ភ្លេចស្មារតី ភ្លាត់ទៅទាំងកាយផង ឯចៅទ្រមាក់ដំរីបានសេចក្តីប្រមាទ ទៅទុកចិត្តសត្វតិរច្ឆានគឺខ្លួនជាន់លើខ្នងដំរី ឈោងដៃទៅចាប់ជើងចៅចាក់ស្មុគជាន់មិនស៊ប់ ក៏ទ្រេតទ្រោតទៅមក ដំរីក៏នឹកសញ្ញាថាម្ចាស់ឲ្យដើរទៅ ទើបវាដើរចេញទៅ ខ្លួនក៏ចាប់ជើងចៅចាក់ស្មុគនោះជាប់ បានក្តីភិតភ័យនឹងក្តីស្លាប់មហិមា ។

ឯសេចក្តីស្លាប់នេះ ជាសភាវៈបុគ្គលខ្លាចក្រៃពេកណាស់ដូចចៅចាក់ស្មុគភ័យនឹងក្តីស្លាប់ ក៏ទទួលជាខ្ញុំបំរើចៅទ្រមាក់ដំរីៗចង់បានគេជាខ្ញុំដល់មិនសមក្តីប្រាថ្នា ក្តីភ័យនឹងមរណកាលដល់ខ្លួន



វិញក៏ត្រឡប់ទទួលខ្លួនជាខ្ញុំអ្នកចាក់ស្មុគនោះវិញ ហេតុនោះបានគតិថា ក្តីមរណភ័យនេះតែមាននៅលើបុគ្គលណាហើយបុគ្គលនោះ អាចហ៊ានទទួលជាបាវជាខ្ញុំគេបានទាំងអស់ ព្រោះក្តីស្រឡាញ់អ្វីៗមិនស្មើនឹងស្រឡាញ់ជីវិតនៃអាត្មាហោង ឯចៅទំពែកទាំងបួនជួយយកអាយុគេ ដោយឥតបញ្ញានឹងពិចារណាមើលទម្ងន់មនុស្សពីរនាក់ ដែលទំលាក់ចុះក្នុងអញ្ចងនោះខ្លួននឹងទ្របានឬពុំបាន ដល់ទ្រពុំបានដោយកំលាំងធ្ងន់ខ្សែអញ្ចងប្រទាញរូបចូល ទាញទាំងខ្លួនឲ្យដល់គ្នាបែកក្បាលស្លាប់ឯខ្លួនឯងវិញ ក្តីប្រាថ្នាពុំសុំរេចទៅបាន ។

ក៏ឯចៅចាក់ស្មុគនោះ លុះក្តីតាមវិតក្កគឺភ្លើសតិភ្លាត់ជើងធាក់ធាងត្នោត ធាក់ទាំងខ្លួនបាននូវក្តីទុក្ខវេទនាដូចពណ៌នាមកនេះគួរអ្នកប្រាជ្ញដឹងដោយទោសកាមវិតក្ក គឺពុំមានសតិដាស់តឿនខ្លួនឡើង ។

មួយទៀត មានរឿងស្រីក្លិង្គម្នាក់ ធ្លាក់ចិត្តគិតចុះក្នុងកាមវិតក្កបានដល់នូវក្តីក្តៅក្រហាយចិត្តជាក្រោយ និទាននោះមានសេចក្តីដូច្នេះ ។

មានស្ត្រីម្នាក់ជាអ្នកក្រ ថ្ងៃមួយទៅទទួលទឹកដោះគោគេបាន

ហើយដាក់នឹងក្អមទូលដើរទៅ លុះដល់កណ្តាលផ្លូវនាងនោះកើតតាមវិតក្កគិតថា កាលណាអញទៅលក់ទឹកដោះនេះ បានប្រាក់ច្រើនហើយអញនឹងទិញមេមាន់មេទាមកចិញ្ចឹម ដល់យូរទៅមេមាន់មេទាបង្កើតកូនសាយច្រើនឡើង អញលក់បានថ្លៃប្រមូលប្រាក់បានច្រើន អញនឹងទិញមេគោមេពពែមកចិញ្ចឹមឲ្យបានច្រើនឡើងអញធ្វើដង្ហៅលក់ទឹកដោះ កើតជាអ្នកមានធំ អញធ្វើផ្ទះថ្មពីរជាន់នៅ អញលោះខ្ញុំស្រី ខ្ញុំប្រុសប្រើក្នុងការអញជានាយដង្ហៅអញលក់ក្នុងមួយព្រឹកៗ បានប្រាក់រាប់រយរាប់ពាន់ញាតិទាំងឡាយសឹងកោតខ្លាចអញទាំងអស់ ដល់មានការធ្វើបុណ្យអ្វីៗ អញនឹងបរិច្ចាគទ្រព្យប្រដាប់ការបុណ្យនោះឲ្យសប្បាយ អញជួលល្ខោនជួលភ្លេងមកលេងហើយអញក៏នាំឲ្យគេមើលផង ។

នាងនោះគិតបណ្តើរដើរបណ្តើរ ក៏ភ្លើសតិភ្លេចអាត្មាលើកដៃទាំងពីររាំចាក់ក្បាច់លោតយ៉ាងទំនងក្បាច់ល្ខោនបារាំង តាំងរេករេខ្លួនទៅផ្សេងៗ ឯក្អមទឹកដោះដែលទូលលើក្បាលនោះក៏ហក់ធ្លាក់ដល់ដីបែកកពប់ទឹកដោះអស់ម្តង ទើបនាងនោះដឹងខ្លួនថាខ្លួនគិតហួសគិតផ្តាស បង់ទឹកដោះអស់ដើមទុនក៏ស្តាយទឹក



ដោះនោះក្រៃពន់ពេក ហើយក្តៅក្រហាយចិត្ត បន្ទោសខ្លួនឯងទៅផ្សេងៗហោង ។

តម្រាក្តៅចិត្តឯងនេះ កើតដោយអំណាចគិតចង់បានវត្ថុកាមកិលេសកាម ហៅថាកាមវិតក្កមែនពិតវិតក្កបីប្រការគឺ កាមវិតក្ក១ ព្យាបាទវិតក្ក១ វិហិង្សាវិតក្ក១ វិតក្ក៣ ប្រការនេះបើមាននៅលើរូបបុគ្គលណាហើយ នាំរូបបុគ្គលនោះឲ្យដល់នូវក្តីក្តៅក្រហាយចិត្តក្នុងកាលក្រោយ ហើយជាទោសឲ្យកើតគេងពុំលក់ស៊ីពុំពិសា ធ្វើកាយាឲ្យស្គាំស្គមទ្រមចូលទៅក្នុងភ្លើងដរាជាឆាប់គួរចូលចិត្តចុះ ។

មួយទៀត ការមិនគួរគិតហើយគិតនេះជាទីនាំចិត្តឲ្យវង្វេងឆ្កួតទៅផ្សេងៗ អ្នកប្រាជ្ញលោកពោលទុកក្នុងគម្ពីរលោកនីតិថាដូច្នេះ ៖

អបត្ថេយ្យំ ន បត្ថេយ្យ
អចិន្តេយ្យំ ន ចិន្តេយ្យ
សភាវមេវ ចិន្តេយ្យ
កាលំ មោឃំ អតិច្ចេយ្យ។

ប្រែថា កុំប្រាថ្នាការមិនគួរប្រាថ្នាបាន កុំគិតរកការមិនគួរ

បុគ្គលគិត គួរគិតតែការសភាពរបស់ពិត កុំប្រាថ្នាកុំទៅគិតការទទេ ។

**ចប់តម្រាកាមវិតក្កទី ៣៨។**

## រឿងសត្វហង្សនិងអណ្តើក

មានហង្សមួយគូតែងនាំគ្នាទៅលេងទឹកស្រះ១ ជានិរន្តរ៍ បានយកអណ្តើកមួយជាសម្លាញ់ ។ ឯអណ្តើកនោះ តែហង្សមកលេងទឹកកាលណា ក៏វាចេញមកនិយាយចរចាប្រស្រ័យជាមិត្រនឹងគ្នា លុះនៅយូរទៅ ស្រះនោះកើតរីងហួតហែង អណ្តើកនឹងនៅពុំបាន ទើបនិយាយនឹងហង្សថា "សម្លាញ់អើយ! ខ្ញុំឯងនឹងនៅអាស្រ័យ ក្នុងស្រះនេះតទៅទៀតពុំបានឡើយ ព្រោះឥតទឹក ដូចសម្លាញ់ឃើញស្រាប់ហើយ" ។

ឯហង្សទាំអគូក៏ថា "បើដូច្នេះមានតែយើងនាំគ្នាទៅអាស្រ័យឯមហាបោក្ខរណីនៅខាងជើងព្រៃហិមពាន្តឯនោះវិញចុះ ដ្បិតស្រះនោះជ្រៅធំទូលាយសប្បាយ ទាំងផលាផលទាំងឡាយជាភក្សាហារក៏បរិបូណ៌ គួរសម្លាញ់ឯងទៅនៅឯមហាស្រះនោះចុះ" ។ អណ្តើកឮហង្សថាដូច្នោះ ក៏តបថា "ខ្លួនខ្ញុំឯងជាសត្វជើងខ្លី លូនដោយផែនដី ធ្វើម្តេចនឹងទៅដល់មហាស្រះ



នោះបាន? ។

ហង្សទាំងគូក៏ថា "ការនាំសម្លាញ់ទៅកាន់មហាស្រះនោះជាភ្នាក់ងារយើងនាំទៅដោយផ្លូវអាកាស គឺយើងខាំពាំឈើស្នែងឲ្យសម្លាញ់ឯងខាំ តោងពីក្រោមឲ្យជាប់យើងទាំងគូនឹងហើរនាំទៅ" ។

អណ្តើកបានស្តាប់ដូច្នោះ ក៏ព្រមតាមទើបហង្សទាំងគូទៅកាត់ឈើស្នែងបាន ក៏ពាំទាំងសងខាងឲ្យអណ្តើកខាំតោងពីក្រោម ហើយហង្សបានហាមអណ្តើកថា "ចូរសម្លាញ់រក្សាមាត់ឲ្យជិតទោះទៅឃើញអ្វីៗក្តី ឬបានឮសព្ទអ្វីៗក្តី កុំបីហាមាត់សួរឬនិយាយពីអ្វីៗឡើយ ព្រោះការដើរដោយផ្លូវអាកាសនោះក្រលំបាកណាស់ តែភ្លាត់មាត់កាលណាក៏វិនាសក្នុងកាលនោះ ហេតុនោះចូរសម្លាញ់ប្រយ័ត្នមាត់កឲ្យមែនទែន" ។ ហង្សទាំងពីរហាមប្រាមអណ្តើកស្រេចហើយ ក៏នាំគ្នាខាំពាំឈើខ្នែងជាបង្គងហើរហោះផ្លោះឡើងលើអាកាសវេហាស៍ មានភក្ត្រាតម្រង់ទៅឧត្តរទិស ។

លុះមកដល់កណ្តាលនគរពារាណសី បណ្តាក្មេងទាំងឡាយ បានឃើញហង្សហើរពាំនាំអណ្តើកដូច្នោះ វាក៏បង្កូកហៅគ្នាគឹកកង

ទំពងឡើងទាំងស្រុកស្រែកប្រាប់គ្នាថា "វ៉ឺយគ្នាយើង ឯងមើល ហង្សវាពាំអណ្តើកនោះ យ៉ាងដាវាយកទៅស៊ីឯលំនៅ ហើយ ឯង" ៗ

ឯអណ្តើកបានឮពាក្យកូនក្មេងថា ហង្សពាំនាំអណ្តើកយកទៅ ស៊ីដូច្នោះ ក៏ខឹងនឹងកូនក្មេង គិតថាអាក្មេងអស់នេះវាស្តីប្រមាថ មាក់ងាយអញពេញទីដាម្តងគួរឬ ហង្សជាសម្លាញ់វានាំអញ ទៅទុកឯមហាស្រះឯណោះទេ នេះវាមកនាំគ្នាពោលថាហង្ស ពាំអញទៅស៊ីវិញ អណ្តើកគិតដូច្នោះហើយក៏កើតទោសានឹង ពួកក្មេង ហាមាត់ឡើងនឹងជេរពួកក្មេងនោះ និមិត្តតែហាមាត់ ឡើងកាលណា ក៏ធ្លាក់អំពីឈើបង្គងចុះមកដល់ផែនដីត្រូវនឹងដី រឹងដីថ្ម បែកស្នូកជាភាគ តូចភាគធំដល់នូវក្តីមរណកាល កណ្តាល ព្រះនគរពារាណសី បណ្តាក្មេងប្រុសស្រីក៏នាំគ្នាទើសសាច់អណ្តើ កនោះយកទៅឲ្យម៉ែឪវាស្លបរិភោគហោងៗ ឯហង្សទាំងពីរ កាលណាបើអណ្តើករបូតមាត់ភ្លាត់ចាកឈើស្នែងធ្លាក់ស្លាប់ហើយ ក៏នាំគ្នាបោលឈើស្នែងនោះចេញចាកមាត់នៃអាត្មាពោលថា "អាអណ្តើកវាមិនដឹកល់នៅក្នុងឱវាទខ្លួនហាម បានជាដល់នូវក្តី វិនាសយ៉ាងនេះ" ថាហើយក៏នាំគ្នាហើរទៅកាន់លំនៅនៃអាត្មា



វិញហោង ៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកមិនសង្រួមបុខទ្វារ គឺមិន រក្សាមាត់ឲ្យល្អ បាននូវក្តីទុក្ខទោសវិនាសប្រាណដូចអណ្តើក នោះឯងគួរចូលចិត្តចុះ ៗ

អនិច្ចាអណ្តើក អណ្តាតខ្វើកៗ បើកមាត់ជេរក្មេង និមិត្តហា មាត់ ភ្លាត់ចាកឈើសែង ធ្លាក់ស្លាប់ខ្លួនឯង ព្រោះមាត់វពិស ៗ

**ចប់តម្រារពីសមាត់ជាគតិទី ៣៩។**

# រឿងសត្វរាជសីហ៍ស្រឡាញ់មេគោ

មានសត្វរាជសីហ៍មួយ ដើរទៅឃើញមេគោរបស់នាយ គោបាលម្នាក់ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់ស្នេហា ចូលទៅសេព កាមដោយមេគោរួចហើយក៏ចូលព្រៃៗ

អាការរាជសីហ៍សេពនឹងមេគោនោះមិនតែម្តងឡើយ សឹង ចូលទៅសេពសព្វៗថ្ងៃ ឯមេគោទាំងឡាយ តាំងតែពីរាជសីហ៍ ចូលកាល់រឿយៗមក ក៏ស្គាំងស្គមទ្រមមាឌ ហើយទាំងមានក្តីភិត ភ័យខ្លាចរាជសីហ៍នោះផង ឯទឹកដោះសោតក៏ចេញមិនបរិបូណ៌ ដូចអំពីមុនៗឡើយ ៗ

នាយគោបាល កាលបើបានឃើញរាជសីហ៍ចូលកាល់មេគោ

ទាំងឡាយរបស់ខ្លួនតែសព្វៗថ្ងៃដំរាបដល់មេគោទាំងឡាយស្គាំងស្គមទ្រមមាឌ នឹងរឹតយកទឹកដោះពុំសូវបាន ដូចកាលមុនៗដូច្នោះ ក៏នាំសេចក្ដីនុ៎ះ ទៅជំរាបដល់មហាសេដ្ឋី ជានាយធំឲ្យជ្រាបហេតុសព្វប្រការ មហាសេដ្ឋីក៏ប្រាប់ឲ្យនាយគោបាលប្រកបថ្នាំពិសពុល យកទៅលាបគូថលាបរោមនៃមេគោទាំងឡាយនោះ ដើម្បីបំពុលរាជសីហ៍ក្នុងកាលដែលវាមកលិធរោមលិធគូថមេគោនោះៗឯង ។

ឯនាយគោបាលក៏ចេញមកស្លថ្នាំពិស បានហើយក៏នាំទៅលាបកាយនៃមេគោ តាមពាក្យមហាសេដ្ឋីបង្គាប់នោះឯង ។

ឯរាជសីហ៍នោះលុះពេលព្រឹកឡើង ក៏ចូលទៅក្នុងហ្វូងគោដល់ហើយក៏ទៅប្រលោមស្នេហា តាំងលិធកាយលិធគូថនៃមេគោនោះឯង លុះពាល់ត្រូវថ្នាំពិសនោះកាលណា ក៏កើតពុលដាលផ្សព្វផ្សាយប្រកាច់ដួលចុះ ដល់នូវមរណកាលកណ្ដាលហ្វូងគោនោះហោង ។

សីហ៍អើយសីហោ ស្លាប់ព្រោះគូថគោ ដោយឥតប្រាជ្ញា គិតស្វែងតែកាម កើតញ៉ាមស្នេហា មិនពិចារណា ឲ្យយល់ខុសត្រូវៗ ខ្លួនជាសត្វព្រៃ ជាតិគោទីទៃ ខុសពូជពង្សផៅ គួរឬ



ទៅធ្វើ អំពើជំទៅ លិធគោពាល់ត្រូវ ថ្នាំពិសពុលក្ស័យ ។

**ចប់តម្រាបុគ្គលស៊ីឬលិធអាហារមិនពិចារណាជាគតិទី ៤០។**

មានសត្វពានរមួយ អាស្រ័យនៅខាងបណ្ណសាលាអាស្រមនៃព្រះមហាឫសីបរមពោធិសត្វ ស្វានោះជាសត្វឡេះឡោះ រពឹសក្នុងការសេពកាម តែឃើញលោតទៅរក ហើយយកអង្គជាតិវាដាក់ក្នុងរន្ធត្រចៀក រន្ធច្រមុះនៃព្រះបរមពោធិសត្វ ធ្វើអាការការលោកិយទៅតាមភាពពាលផ្សេងៗ ។

ឯបរមពោធិសត្វបានយល់ស្វាធ្វើអាការដូច្នោះព្រអង្គនឹងបានប្រហារទះទាត់ស្វានោះចេញ ក៏ឥតអង្គីមាន ព្រោះព្រះទ័យតាំងនៅក្នុងកិច្ចចំរើនឈានសមាធិគុណ ឯកិរិយាពាលរបៀតបៀនធ្វើនូវអសទ្ធម្មជាផ្លូវមេថុននឹងសោតទ្វារ ឃានទ្វារ នៃព្រះមហាឥសីបរមពោធិសត្វនោះតែរឿយៗ វៀងៗមក ។

លុះនៅយូរមក មានកាលថ្ងៃមួយ ចៅពានរចេញទៅស្វែងរកអាហារនឹងបរិភោគ បានទៅឃើញអណ្ដើកខ្មៅ១ ហាមាត់ដេកលក់នៅក្នុងទី១ ពានរជាសត្វរពឹស ក៏ចូលទៅហើយ ដាក់អង្គជាតិខ្លួនទៅក្នុងមាត់អណ្ដើក ធ្វើអសទ្ធម្មដោយទ្វារមាត់អណ្ដើកនោះឯង ។

ឯអណ្តើកនោះ លុះភ្ញាក់ដឹងខ្លួនហើយក៏ខាំសង្កត់អង្គជាតិស្វានោះ ខ្ជាប់ពុំលែងឡើយ ឯពានរក៏ឈឺពេកឡើងតាំងបើកមាត់អណ្តើកឲ្យហាក៏បើកពុំបាន អណ្តើកក៏រឹតតែខាំសង្កត់ចុះ ពានរនិយាយអង្វររលួងលោមឲ្យអណ្តើកលែងដូចម្តេចៗ អណ្តើកក៏ពុំលែងឡើយ ចៅពានរបានក្តីទុក្ខវេទនាពន់ពេកណាស់ ទើបគិតថា ក្តីទុក្ខអញម្តងនេះជាទុក្ខធំបំផុតនឹងរកលោកអញ អ្នកឯណា ជាពេទ្យជួយបន្ទោបង់រោគនេះយល់ពុំមាន មានតែព្រះឥសីសីលាទើបអាចជួយកែរោគនេះបាន គិតហើយចៅពានរឱនកាយទ្រអណ្តើកដោយដៃទាំងពីរ ដើរឱនៗកំប្រោនប្រាណចូលទៅកាន់ទីឋាននៃព្រះបរមពោធិសត្វៗ បែរទៅយល់ពានរទ្រអណ្តើកមកដូច្នោះ ក៏ជ្រាបហេតុនោះមួយរំពេចថា អស្វានេះវាជាសត្វពាល ធ្លាប់មកបៀតបៀនអញរឿយៗ ឥឡូវទៅត្រូវលើមាត់អណ្តើកៗ កាលណានឹងអត់បានដូចអញគង់ខាំផ្ទាលយ៉ាងនេះមិនលែង គិតហើយព្រះឥសីក៏ត្រាសសួរចំអកទៅកាន់ស្វានោះថា "ហៃចៅក្របីអើយ ថ្ងៃនេះចៅស្វែងអាហារភោក្តា ចៅបានផ្លែខ្នុរ ឬផ្លែធូរេនយកមកប្រគេនអាត្មាចៅក្របិ? ៗ



ឯពានរឈឺនឹងអណ្តើក វាមិតខាំខ្លាំងណាស់ក៏ធ្វើមុខជូរខំទូលទៅថា " បពិត្រលោក ព្រះតាបសមានធម៌សប្បុរសប្រសើរអើយ ខ្ញុំព្រះករុណានេះបាននូវក្តីទុក្ខវេទនា កើតអំពីអណ្តើកវាខាំពូជឈើស្មើរនឹងស្លាប់ហើយ ព្រះគុណអើយ ជួយប្រោសមេត្តាបង្ហាមាត់អណ្តើក ឲ្យពូជខ្ញុំបានរបើកចេញអំពីមាត់អណ្តើកក្នុងគ្រានេះទៅ ឲ្យតែខ្ញុំបានរួចអំពីទុក្ខនេះហើយ ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំរាងចាលហើយ ខ្ញុំលែងប្រព្រឹត្តការអសទ្ធម្មតទៅទៀតហើយព្រះករុណា" ៗ

ឯព្រះបរមពោធិសត្វ បានឮស្វាពោលពាក្យដូច្នោះ ក៏មានព្រះហឫទ័យអាសូរករុណា ទើបត្រាស់ទៅកាន់អណ្តើកនោះថា "ហៃបាកច្ឆបះអើយ ចៅឯងជាកស្សបគោត្រ ឯខាងចៅក្របិជាកោណ្ឌញ្ញគោត្រ គោត្រទាំងពីរក៏ពុំឆ្ងាយអំពីគ្នា ហេតុនោះចូរអាណិតមេត្តាអត់ទោសចៅក្របិនេះម្តងទៅចុះ ចូរលែងខាំអង្គជាតិចៅក្របិនេះទៅ ដោយគ្នាទទួលខុសហើយទទួលរាងចាលហើយ" ៗ ឯអណ្តើកបានស្តាប់ពាក្យពោធិសត្វហើយ ក៏ហាមាត់បើកឲ្យស្វានោះរួចចាកក្តីទុក្ខក្នុងកាលនោះហោង ៗ

ចៅពានរបានរួចអំពីមាត់អណ្តើកហើយក៏កើតអៀនខ្មាស់

ពោធិសត្វ ទើបក្រាបសំពះពោធិសត្វហើយចេញចាកទីនោះ
ទៅនៅទី១ ឆ្ងាយអំពីអាស្រមបរមពោធិសត្វ ពុំបានមកបៀត
បៀនពោធិសត្វតទៅទៀតឡើយ ចាប់ដើមពីថ្ងៃនោះ
ហោង ៗ

រឿងនិទាននេះ មានសេចក្ដីពិស្ដារនៅក្នុងគម្ពីរតិកនិបាតឯ
ណោះ ក្នុងតម្រានេះខ្ញុំបាទទាញមកសំដែងតែប៉ុណ្ណោះដោយ
សង្ខេប ទុកជាបែបតតិដល់បុគ្គលអ្នកល្មោភក្នុង កិលេសកាម
ប្រព្រឹត្តការទៅក្នុងព្រង់ ដែលពុំមែនជាទ្វារមេថុនតាមធម្មតា
លោកិយ បានសេចក្ដីក្ដៅក្រហាយ ដូចនិទានចៅពានរដែលសំ
ដែងទុកមកនេះ អ្នកមានប្រាជ្ញាគួរពិចារណាទៅទៀតចុះ ៗ

ស្វាអើយចៅស្វា ចៅល្មោភតណ្ហា មិនថាទ្វារអ្វី ឃើញតែ
ចន្លោះ ទៅបោះប៉ោលថ្មី ត្រូវកាឡ្យកិណី លើមាត់អណ្ដើក ៗ
កើតក្ដៅក្រហាយ ខំខ្វេះកកាយ មិនងាយរបើក បង់កេរ្ដិ៍បង់
ខ្មាស់ ផ្ដាលព្រោះចិត្តចើក ទៅលេងអណ្ដើក អន្តរធានខ្លួន ៗ

**ចប់តម្រារពីសលិង្គ ជាតតិទី ៤១។**

**ចប់ភាគទី ៧ តែប៉ុណ្ណោះ។**